## នៅក្នុងការបោះពុម្ពផ្សាយនេះ

## ចេញលើកទី ៥៖ រដូវរងា ឆ្នាំ ២០២៣

សូមស្វាគមន៍មកកាន់ការបោះពុម្ពផ្សាយនៃព្រឹត្តិប័ត្រប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាល ដែលលោកអ្នកនឹងឃើញព័ត៌មានថ្មីៗអំពី ការរៀបចំជាថ្មីនៃក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ និងអ្នកដឹកនាំថ្មី ពានរង្វាន់សម្រាប់ជោគជ័យក្នុងជីវិតរបស់សមាជិកក្រុមប្រឹក្សាភិបាល Wilkerson ការិយាល័យសាលាឆាផ័រ និង របាយការណ៍តាមដានការរីចម្រើនថ្មីៗរបស់ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails)។

## សារចេញពីប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលដែលទើបជាប់ឆ្នោតថ្មីៗនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ មានកិត្តិយស និងសូមបន្ទាបខ្លួន សម្រាប់ឱកាសបម្រើក្នុងតួនាទីនេះ។ ខ្ញុំសូមថ្លែងអំណរគុណដល់សហការីរបស់ខ្ញុំ ចំពោះការបោះឆ្នោតជឿជាក់មកលើរូបខ្ញុំ។ ទោះយ៉ាងណាក៏ដោយ គ្មាននរណាម្នាក់ដែលមិនពឹងផ្អែកអ្នកដទៃនោះទេ ហើយខ្ញុំទន្ទឹងរង់ចាំការគាំទ្រជាបន្តបន្ទាប់របស់ក្រុមប្រឹក្សាភិបាល នៅពេលដែលយើងបន្តធ្វើការងារសម្រាប់ក្មេងរបស់យើង។

ប្រសិនបើខ្ញុំមិនមែនជាអតីតសិស្សដែលទទួលបានអត្ថប្រយោជន៍ពីការអប់រំនៅសាលារដ្ឋរបស់ខ្ញុំនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ានោះទេ ពីដំបូងឡើយនៅ អនុវិទ្យាល័យ Leeds ហើយបន្ទាប់មកបញ្ចប់ការសិក្សាពីវិទ្យាល័យ Germantown នោះខ្ញុំក៏នឹងមិនបានស្ថិតនៅក្នុងទីនេះនៅថ្ងៃនេះដែរ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំដឹងនៅក្នុងចិត្តរបស់ខ្ញុំថា មូលដ្ឋានគ្រឹះនៃការអប់រំរបស់ខ្ញុំគឺជាអ្វីដែលនាំឱ្យខ្ញុំទទួលបានមុខតំណែងនេះ និងជាមេធាវីនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

ខ្ញុំក៏ដឹងដែរថា សហគមន៍ទាំងមូលបានបណ្តុះបណ្តាលខ្ញុំកាលពីក្មេង ហើយនាំខ្ញុំមកដល់ទីនេះ ជាកន្លែងដែលសាធារណៈជនទុកចិត្ត។ ខ្ញុំដឹង ដោយសារតែខ្ញុំធ្លាប់ជួបប្រទះនឹងភាពគ្មានផ្ទះសម្បែង ការព្យាយាមប្រឆាំងប្រឆាំងនឹងគ្រឿងញៀន និងផលប៉ះពាល់របស់វាមកលើសហគមន៍របស់យើង និងការប៉ះទង្គិចស្ទើរតែទាំងអស់ដែលក្មេងរបស់យើងកំពុងជួបប្រទះសព្វថ្ងៃនេះ។ ខ្ញុំសូមសរសើរដល់សហគមន៍ទាំង

មូលរបស់ខ្ញុំ (ម្ដាយ ឪពុក គ្រួសារ និងអ្នកអប់រំ) ដែលបានរួមគ្នាគាំទ្រខ្ញុំក្នុងពេលលំបាក ក្នុងវិធីមួយដើម្បីកាត់បន្ថយការរារាំងទាំងនោះ។

ក្ដីសុបិនរបស់ខ្ញុំសម្រាប់ក្មេងគ្រប់រូបនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យាគឺសុំឱ្យសហគមន៍របស់ពួកគេរួមដៃគ្នាជួយពួកគេ ដើម្បីកាត់បន្ថយការរារាំងជាច្រើន ដែលក្មេងរបស់យើងកំពុងប្រឈមមុខនៅពេលនេះ។ តាមការរួបរួមគ្នា យើងទាំងអស់គ្នាអាចជាសហគមន៍នោះ។

Reginald L. Streater, Esq.

ប្រធានក្រុមប្រឹក្សាអប់រំ

## ក្រុមប្រឹក្សាជ្រើសរើសអ្នកដឹកនាំថ្មីសម្រាប់ឆ្នាំ ២០២៣

នៅក្នុងកិច្ចប្រជុំដើម្បីស្វែងយល់បន្ថែមកាលពីខែ ធ្នូ ឆ្នាំ ២០២២ ក្រុមប្រឹក្សាអប់រំបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួនឡើងវិញ ហើយជ្រើសរើសអ្នកដឹកនាំថ្មី៖ លោក Reginald L. Streater ជា ប្រធាន និង អ្នកស្រី Mallory Fix-Lopez ជា អនុប្រធាន ដែលបានចាប់ផ្ដើមបម្រើសម្រាប់រយៈពេលមួយឆ្នាំរបស់ពួកគេក្នុងពេលភ្លាមៗនេះ។ ពួកគេជំនួស អ្នកស្រី Joyce S. Wilkerson ដែលជាប្រធាន និង អ្នកស្រី Leticia Egea-Hinton ដែលជាអនុប្រធាន ដែលបានលាលែងពីតំណែងជាអ្នកដឹកនាំរបស់ពួកគេ ប៉ុន្តែនឹងបន្តនៅក្នុងក្រុមប្រឹក្សាភិបាលតទៅទៀត។

លោក Streater ដែលត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ២០២១ ជឿជាក់ថា ការអប់រំសាធារណៈមិនត្រឹមតែជាសិទ្ធិស៊ីវិលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសិទ្ធិរបស់មនុស្សផងដែរ។ គាត់បានបញ្ចប់ការសិក្សាពី វិទ្យាល័យ Germantown ហើយមានកូនពីរនាក់រៀននៅសាលារដ្ឋ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា។ ប្រធានក្រុមប្រឹក្សាភិបាល Streater ជាមេធាវីនៅ Berger Montague ដែលមានមុខងារជាអ្នកតំណាងខាងការងារ និងប្រាក់ឈ្នួលដែលគេមិនបង់ឱ្យ ជាអ្នកគាំទ្រដ៏ខ្លាំងក្លាសម្រាប់អ្នកដែលគ្មានសិទ្ធិអំណាចខាងច្បាប់ជាប្រវត្តិសាស្ត្រ និងសាធារណៈជនទូទៅ។

អ្នកស្រី Fix-Lopez ត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ២០១៨ បច្ចុប្បន្ននេះជាអនុសាស្ត្រាចារ្យភាសាអង់គ្លេស-ESL (អង់គ្លេសជាភាសាទីពីរ) នៅ អនុមហាវិទ្យាល័យនៃទីក្រុងហ្វីឡាដែលហ្វ្យា (Community College of Philadelphia) និងជាសមាជិក ផ្នែកភាសាវិទ្យាអប់រំក្រោយពេលបញ្ចប់បរិ

ញ្ញាប័ត្រនៅសាកលវិទ្យាល័យ ផិនស៊ីលវេនញ៉ា (Educational Linguistics at the Graduate School of Education at the University of Pennsylvania)។ អនុប្រធាន Fix-Lopez ក៏ពិគ្រោះយោបល់ជារឿយៗជាមួយស្ថាប័នស្រាវជ្រាវជីវវេជ្ជសាស្ត្រទូទាំងសហរដ្ឋអាមេរិក ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈដែលផ្តោតលើការទាក់ទងនឹងវិទ្យាសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់អ្នកស្រាវជ្រាវអន្តរជាតិរបស់ពួកគេ។ អ្នកស្រីរស់នៅប៉ែកខាងត្បូងនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ជាមួយប្តី និងកូនពីរនាក់ កូនម្នាក់រៀននៅសាលា George W. Childs ។

អ្នកស្រី Wilkerson បានមានប្រសាសន៍ថា «សមាជិកក្រុមប្រឹក្សាភិបាល Egea-Hinton និងខ្ញុំមានកិត្តិយសបម្រើក្នុងតួនាទីជាអ្នកដឹកនាំនៅក្នុងក្រុមប្រឹក្សាភិបាលអប់រំតាំងពីឆ្នាំ ២០១៨ មក»។ «ទោះជាយ៉ាងណាក៏ដោយ យើងមានអារម្មណ៍ថា នេះជាពេលល្អសម្រាប់អ្នកដឹកនាំជំនាន់ក្រោយនាំមកនូវចំណង់ចំណូលចិត្តរបស់ពួកគេសម្រាប់ការកែលម្អការអប់រំនៅសាលារដ្ឋ ជំនាញវិជ្ជាជីវៈរបស់ពួកគេ និងស្មារតីរួបរួមរបស់ពួកគេ ចំពោះភាពជាអ្នកដឹកនាំក្នុងក្រុមប្រឹក្សា ដើម្បីជំរុញការងាររបស់យើងទៅមុខឱ្យប្រកបដោយប្រសិទ្ធភាព។»

អ្នកស្រី Wilkerson ត្រូវបានតែងតាំងជាគណៈកម្មាធិការកែទម្រង់សាលា (SRC) ក្នុងឆ្នាំ ២០១៦ ដោយចៅហ្វាយក្រុង Jim Kenney ហើយត្រូវបានតែងតាំងជាប្រធាននៃគណៈកម្មាធិការកែទម្រង់សាលារៀន (SRC) ដោយអភិបាលរដ្ឋ Tom Wolf ។ អ្នកស្រី Wilkerson បានដឹកនាំការផ្លាស់ប្តូររបស់ក្រសួងអប់រំ ពី SRC ដែលគ្រប់គ្រងដោយរដ្ឋ ទៅជាក្រុមប្រឹក្សាភិបាលអប់រំដែលគ្រប់គ្រងដោយតំបន់ ក្នុងឆ្នាំ ២០១៨ នៅពេលដែល អ្នកស្រី Egea-Hinton និងអ្នកស្រី Fix-Lopez ត្រូវបានតែងតាំងជាក្រុមប្រឹក្សាភិបាល ដោយ ចៅហ្វាយក្រុង Kenney ។ បន្ទាប់មកក្រុមប្រឹក្សាភិបាលបានជ្រើសរើស អ្នកស្រី Wilkerson ជាប្រធានក្រុមប្រឹក្សាភិបាល។

បន្ទាប់មកក្រុមប្រឹក្សាភិបាលបានមើលខុសត្រូវការផ្លាស់ប្តូរក្រសួងអប់រំដែលស្ថិតនៅក្នុងបញ្ហាហិរញ្ញវត្ថុ និងបញ្ហាសិក្សា ឱ្យទៅជាក្រសួងអប់រំដែលធ្វើឱ្យលទ្ធផលអប់រំដែលប្រសើរឡើងសម្រាប់សិស្ស ខណៈពេលដែលក្រសួងអភិវឌ្ឍការគ្រប់គ្រងហិរញ្ញវត្ថុបានរឹងមាំ ដោយទទួលបានចំណាត់ថ្នាក់នៃការវិនិយោគពីក្រុមហ៊ុន Moody's Investor Services ជាលើកដំបូង តាំងពីឆ្នាំ ១៩៧៧ មក។ ពួកគេក៏បានដឹកនាំការងាររបស់ក្រុមប្រឹក្សាភិបាលដើម្បីបង្កើត និងអនុវត្តតាម គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails) ផងដែរ ដែលជាផែនការដែលបង្កើតឡើងដើម្បីបង្កើនជោគជ័យរបស់សិស្ស ខណៈពេលដែលផ្តល់នូវល័ក្ខខ័ណ្ឌ

ចាំបាច់ដែលគាំទ្រដល់ការរៀនសូត្រ។ ថ្មីៗនេះ អ្នកស្រី Egea-Hinton បានដឹកនាំក្រុមប្រឹក្សាភិបាលក្នុងការស្វែងរកអគ្គនាយកក្រសួងអប់រំថ្មី ដែលឈានដល់ការតែងតាំង អគ្គនាយកក្រសួងអប់រំ Tony B. Watlington Sr., Ed.D ដែលមានប្រវត្តិបង្ហាញឱ្យឃើញពីការគាំទ្រ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails)។

ចៅហ្វាយក្រុង Jim Kenney បានមានប្រសាសន៍ថា «ប្រធាន Wilkerson និង អនុប្រធាន Egea Hinton សមនឹងទទួលការទទួលស្គាល់ និងការដឹងគុណពីយើង សម្រាប់តួនាទីដ៏សំខាន់ដែលពួកគាត់បានចូលរួម ចំពោះជោគជ័យនៃការវិលត្រឡប់មកគ្រប់គ្រងសាលាវិញដោយរដ្ឋាភិបាលក្នុងតំបន់ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា»។ «នោះជាកិត្តិយសក្នុងការតែងតាំងពួកគាត់ឱ្យធ្វើជាក្រុមប្រឹក្សាអប់រំក្នុងតំបន់ដំបូងគេ ក្នុងរយៈពេលជិតពីរទសវត្សរ៍នេះ។ ហើយអស់រយៈពេលជាង ៤ ឆ្នាំ មកនេះ ពួកគាត់បានបង្ហាញពីការលះបង់របស់ពួកគាត់យ៉ាងខ្ជាប់ខ្ជួន ដើម្បីជោគជ័យរបស់សិស្ស និងភាពជាអ្នកដឹកនាំដ៏ខ្លាំងក្លាក្នុងអំឡុងពេលនៃការផ្លាស់ប្តូរ និងបញ្ហាធំៗជាច្រើនដែលត្រូវប្រឈម។ ខ្ញុំឲ្យតម្លៃលើប្រាជ្ញា ការឧស្សាហ៍ព្យាយាម និងជំនាញរបស់ពួកគាត់ ក្នុងនាមជាដៃគូក្នុងការគាំទ្រដល់ក្មេងៗ និងក្រុមគ្រួសារក្នុងទីក្រុងយើង ហើយខ្ញុំសូមសម្តែងនូវកត្តញ្ញូតាចំពោះការបម្រើក្នុងក្រុមប្រឹក្សាភិបាលរបស់គាត់ជាបន្ត។»

«អគ្គនាយកក្រសួងងប់រំ Tony B. Watlington, Sr., Ed.D. បានមានប្រសាសន៍ថា «ក្នុងនាមជាក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ្នកស្រី Wilkerson និង អ្នកស្រី Egea-Hinton ចំពោះភាពជាអ្នកដឹកនាំ ការលះបង់ និងការបម្រើសាធារណៈជន របស់ពួកគាត់ដល់ក្រសួងអប់រំ និងសិស្សក្នុងទីក្រុងហ្វីឡាដែលហ្វ្យា»។ «ពួកគាត់បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងខ្ជាប់ខ្ជួនក្នុងការធ្វើជាអ្នកដឹកនាំ និងជាសំឡេងសម្រាប់ទីក្រុង និងធ្វើឱ្យប្រាកដថាសិស្សរបស់យើងនៅទីក្រុងហ្វីឡាដែលហ្វ្យា ទទួលបានការអប់រំដែលមានគុណភាពខ្ពស់ ជាពិសេសក្នុងអំឡុងពេលដ៏លំបាកបំផុតមួយចំនួនរបស់ក្រសួងអប់រំ ជាពិសេសទៀតក្នុងអំឡុងពេលមានជំងឺរាតត្បាត។ នៅពេលដែលពិភពលោករាំងស្ទះដំណើរ ការប្តេជ្ញាចិត្តរបស់ អ្នកស្រី Wilkerson និង អ្នកស្រី Egea-Hinton ចំពោះក្មេងទាំងអស់របស់យើង មិនដែលបាត់បង់ឡើយ។ ខ្ញុំទន្ទឹងរង់ចាំសហការជាមួយប្រធាន និងអនុប្រធាន ក្រុមប្រឹក្សាភិបាលថ្មី នៅពេលដែលយើងខិតខំដើម្បីសម្រេចបាននូវ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails) ខណៈពេលដែលខិតខំឱ្យក្លាយទៅជាក្រសួងអប់រំដែលធំនៅក្នុងទីក្រុងឱ្យមានការរីកចម្រើនដ៏លឿនបំផុតនៅក្នុងប្រទេស។»

ក្រុមប្រឹក្សាភិបាលអប់រំមានតួនាទីជាក្រុមគ្រប់គ្រងសម្រាប់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា និង ត្រួតពិនិត្យ គោលការណ៍ និងការសម្រេចចិត្តលើថវិកាទាំងអស់របស់ក្រសួងអប់រំ។ លើសពីនេះ ក្រុមប្រឹក្សាភិបាលតែងតាំងអគ្គនាយកក្រសួងអប់រំ និងជាអ្នកផ្តល់សិទ្ធិឱ្យសាលាឆាធ័រទាំងអស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា។ យោងតាម គោលការណ៍ 004 ប្រធានក្រុមប្រឹក្សាភិបាលធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំងអស់ ចុះហត្ថលេខាផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធ កិច្ចសន្យា និងឯកសារផ្សេងៗដែលទាក់ទងនឹងធុរៈកិច្ចរបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវការហត្ថលេខារបស់ប្រធាន។ លើសពីនេះ ប្រធានបំពេញភារកិច្ចអ្វីមួយដែលក្រុមប្រឹក្សាភិបាលប្រគល់ជូន និងកំណត់ដោយច្បាប់។

អនុប្រធានក្រុមប្រឹក្សាភិបាលបំពេញមុខងារក្នុងពេលប្រធានអវត្តមាន តាមការបង្គាប់របស់ក្រុមប្រឹក្សាភិបាល។ លើសពីនេះ អនុប្រធានមានតួនាទីជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍អ្វីមួយ នៅពេលដែលប្រធានគណៈកម្មាធិការ ឬអនុប្រធានអវត្តមាន។ សមាជិកក្រុមប្រឹក្សាភិបាល Egea-Hinton បានបម្រើការជាសហប្រធាននៃគណៈកម្មាធិការហិរញ្ញវត្ថុ និងសេវាអគារសិក្សា និងជាសមាជិកនៃគណៈកម្មាធិការផ្នែកដៃគូ និងទំនាក់ទំនងជាមួយសហគមន៍។ អ្នកស្រីក៏ជាអ្នកទំនាក់ទំនងក្រុមប្រឹក្សាភិបាលសម្រាប់ការិយាល័យសេវាកម្មជម្រះបញ្ជីផងដែរ។

ក្រុមប្រឹក្សាភិបាលមានសមាជិកប្រាំបួននាក់ ដែលត្រូវបានតែងតាំងដោយចៅហ្វាយក្រុង និងបញ្ជាក់ដោយក្រុមប្រឹក្សាក្រុង។ បន្ថែមពីលើ ប្រធាន Streater និង អនុប្រធាន Fix-Lopez សមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្នរួមមាន៖ Sarah-Ashley Andrews, Julia Danzy, Leticia Egea-Hinton, Chau Wing Lam, Lisa Salley, Cecelia Thompson និង Joyce S. Wilkerson ។

## សមាជិកក្រុមប្រឹក្សាភិបាល Joyce Wilkerson ទទួល ពានរង្វាន់សម្រាប់ជោគជ័យក្នុងជីវិតដ៏មានកិត្យានុភាព (Prestigious Lifetime Achievement Award)

សមាជិកក្រុមប្រឹក្សាភិបាល Joyce S. Wilkerson បានទទួល ពានរង្វាន់ Benjamin Elijah Mays សម្រាប់ជោគជ័យក្នុងជីវិត (Benjamin Elijah Mays Lifetime Achievement Award) សម្រាប់ការប្តេជ្ញាចិត្តដ៏យូរអង្វែងរបស់អ្នកស្រីចំពោះតម្រូវការអប់រំរបស់ក្មេងដែលរៀននៅសាលាក្នុងទីក្រុង។ ក្រុមប្រឹក្សាអប់រំនៅក្នុងទីក្រុង [Council of Urban Boards of Education (CUBE)] ផ្តល់រង្វាន់នេះជារៀងរាល់ឆ្នាំ ដើម្បីទទួលស្គាល់សមាជិកក្រុមប្រឹក្សាសាលាបច្ចុប្បន្នកាល ឬអតីតកាល ដែលបានធ្វើឱ្យមានភាពល្អប្រសើរដល់សិស្សដែលពួកគេបម្រើ។

នៅឆ្នាំ ២០១៦ អ្នកស្រី Wilkerson ត្រូវបានតែងតាំងជា គណៈកម្មាការកែទម្រង់សាលារៀន (School Reform Commission) ដោយចៅហ្វាយក្រុង Kenney ហើយបន្ទាប់មក អភិបាលរដ្ឋ Wolf បានតែងតាំងអ្នកស្រីជាប្រធានរបស់ខ្លួននៅឆ្នាំ ២០១៦។ នៅឆ្នាំ ២០១៨ ចៅហ្វាយក្រុងបានតែងតាំង អ្នកស្រី Wilkerson ជាក្រុមប្រឹក្សាអប់រំ ហើយបន្ទាប់មកសមាជិកក្រុមប្រឹក្សាភិបាលបានជ្រើសរើសអ្នកស្រីជាប្រធាន ដែលជាការិយាល័យដែលអ្នកស្រីកាន់កាប់រហូតដល់ខែ ធ្នូ ឆ្នាំ ២០២២។

ក្នុងអំឡុងពេលកាន់តំណែងរយៈពេលប្រាំមួយឆ្នាំនៅក្រសួងអប់រំ អ្នកស្រី Wilkerson បានដឹកនាំការផ្លាស់ប្តូររបស់ក្រសួងអប់រំពី គណៈកម្មាធិការកែទម្រង់សាលារៀន ដែលគ្រប់គ្រងដោយរដ្ឋ ទៅជាក្រុមប្រឹក្សាអប់រំដែលគ្រប់គ្រងដោយទីក្រុង ក្នុងឆ្នាំ ២០១៨។ បន្ទាប់មកក្រុមប្រឹក្សាភិបាលបានត្រួតត្រាការផ្លាស់ប្តូររបស់ក្រសួងអប់រំដែលមានបញ្ហាហិរញ្ញវត្ថុ និងការសិក្សា ឱ្យក្លាយទៅជាក្រសួងអប់រំដែលប្រសើរឡើងសម្រាប់សិស្ស ខណៈពេលដែលក្រសួងបង្កើតការគ្រប់គ្រងហិរញ្ញវត្ថុឱ្យរឹងមាំ ដោយទទួលបានចំណាត់ថ្នាក់នៃការវិនិយោគពី Moody's Investor Services ជាលើកដំបូង តាំងពីឆ្នាំ ១៩៧៧ មក។

ក្រោមការដឹកនាំរបស់ អ្នកស្រី Wilkerson ក្រុមប្រឹក្សាភិបាលបានបង្កើតភាពជាដៃគូដែលបានបង្កើតការគាំទ្របន្ថែមសម្រាប់សិស្ស និងបានធ្វើការបណ្តាក់ទុនដើម្បីជំរុញផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល ដែលត្រូវបានគេស្គាល់ថាជា គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails)។ នៅឆ្នាំ ២០១៩ អ្នកស្រី Wilkerson បានដឹកនាំការងាររបស់ក្រុមប្រឹក្សាភិបាលដើម្បីបង្កើត និងអនុវត្ត គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails) ជាផែនការដែលបានរៀបចំឡើងដើម្បីបង្កើនជោគជ័យរបស់សិស្ស ខណៈពេលដែលផ្តល់នូវល័ក្ខខ័ណ្ឌចាំបាច់ដែលគាំទ្រដល់ការរៀនសូត្រ។

ថ្មីៗនេះ អ្នកស្រី Wilkerson បានចូលរួមក្នុងការស្វែងរកអគ្គនាយកក្រសួងអប់រំថ្មីរបស់ក្រុមប្រឹក្សាភិបាលក្នុងរយៈពេលប្រាំមួយខែ។ ក្រោមការដឹកនាំរបស់អតីតអនុប្រធានក្រុមប្រឹក្សាភិបាល Leticia Egea-Hinton ក្រុមប្រឹក្សាភិបាលបានធ្វើការផ្សព្វផ្សាយនៅតាមសហគមន៍នានា ជួលក្រុមហ៊ុនផ្នែកស្រាវជ្រាវ និងតែងតាំងគណៈកម្មាធិការប្រឹក្សាស្វែងរកអគ្គនាយកក្រសួងអប់រំ ដែលរួមបញ្ចូលសំឡេងរបស់សហគមន៍ចម្រុះនៅក្នុងដំណើរការស្វែងរកនេះ។ ការស្វែងរកបានឈានដល់ការតែងតាំងអគ្គនាយកក្រសួងអប់រំ Tony B. Watlington Sr., Ed.D ដែលមានបទពិសោធន៍ផ្នែកអប់រំអស់រយៈពេល ២៧ ឆ្នាំ និង

មានប្រវត្តិដែលបង្ហាញឱ្យឃើញថាមានការគាំទ្រដល់គោលបំណងដែលមាននៅក្នុង Goals & Guardrails។

សមាជិកក្រុមប្រឹក្សាភិបាល Wilkerson បានមានប្រសាសន៍ថា «ខ្ញុំមានកិត្តិយសណាស់ដែល ក្រុមប្រឹក្សាអប់រំសិស្សដែលរៀនក្នុងទីក្រុង បានទទួលស្គាល់ការងាររបស់ខ្ញុំក្នុងវិស័យអប់រំនៅសាលារដ្ឋ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលសម្រាប់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា»។ "ខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការផ្លាស់ប្តូរការអប់រំសាលារដ្ឋក្នុងទីក្រុងហ្វីឡាដែលហ្វ្យា ដើម្បីឱ្យក្មេងរបស់យើងទាំងអស់មានជំនួយ និងឱកាសដែលពួកគេត្រូវការដើម្បីសិក្សា រីកចម្រើន និងសម្រេចបាននូវសក្តានុពលដ៏អស្ចារ្យបំផុតរបស់ពួកគេ។»

ពានរង្វាន់នេះត្រូវបានប្រកាសនៅក្នុង សន្និសិទសមាគមក្រុមប្រឹក្សាសាលាជាតិ (National School Board Association Conference) នៅទីក្រុង ម៉ៃអាមី នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០២២។ បន្ទាប់មក *កាសែតក្រុមប្រឹក្សាសាលាអាមេរិកាំង (The American School Board Journal)* បានបោះពុម្ពផ្សាយក្នុងខែ មករា ឆ្នាំ ២០២៣ អត្ថបទ ដែលផ្តោតលើភាពជាអ្នកដឹកនាំរបស់ អ្នកស្រី Wilkerson ក្នុងការអប់រំសិស្សដែលរៀននៅសាលារដ្ឋ និងការប្តេជ្ញាចិត្តរបស់អ្នកស្រីក្នុងការធ្វើឱ្យជោគជ័យរបស់សិស្សកាន់តែប្រសើរឡើង។ និងធ្វើយ៉ាងណាឱ្យមានឱកាសសមធម៌សម្រាប់សិស្សទាំងអស់ក្នុងការសិក្សា ការរីកចម្រើន និង ជោគជ័យ។

ពានរង្វាន់នេះត្រូវបានដាក់ឈ្មោះសម្រាប់ Benjamin Elijah Mays ដែលបានចូលរួមជាមួយ ក្រុមប្រឹក្សាអប់រំនៅទីក្រុង អ៊ែតឡិនតា (Atlanta) ក្នុងឆ្នាំ ១៩៦៩ ហើយបានបម្រើការជាប្រធានរបស់ខ្លួនពីឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៨១។ ក្នុងអំឡុងពេលដែលគាត់នៅក្នុងក្រុមប្រឹក្សាភិបាល លោក Mays បានធ្វើការឥតឈប់ឈរដើម្បីផ្តល់ឱកាសអប់រំស្មើៗគ្នាដល់ក្មេងទាំងអស់។ គាត់ត្រូវបានគេចងចាំចំពោះភាពជាអ្នកដឹកនាំ និងការបម្រើដ៏ឆ្នើមរបស់គាត់ ក្នុងនាមជាអ្នកប្រាជ្ញ គ្រូបង្រៀន រដ្ឋមន្ត្រី អ្នកណែនាំ អ្នកនិពន្ធ និងជាសកម្មជនសិទ្ធិមនុស្ស។

## ការិយាល័យសាលាឆាធ័រ គាំទ្រក្រុមប្រឹក្សាភិបាលក្នុងតួនាទីជាអ្នកផ្តល់អំណាចឱ្យសាលាឆាធ័រ

ក្នុងនាមជាក្រុមគ្រប់គ្រងសម្រាប់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា តួនាទីចម្បងរបស់ក្រុមប្រឹក្សា

អប់រំគឺត្រួតពិនិត្យគោលការណ៍ និងការសម្រេចចិត្តលើថវិកាទាំងអស់សម្រាប់ក្រសួងអប់រំ។ ប៉ុន្តែក្រុមប្រឹក្សាភិបាលមានភារកិច្ចសំខាន់ពីរផ្សេងទៀត។ មួយគឺតែងតាំង និងវាយតម្លៃអគ្គនាយកក្រសួងអប់រំ។ មួយទៀតគឺធ្វើជាអ្នកឱ្យអំណាចដល់អគារសាលាឆាធ័រទាំងអស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា។

ការជួយក្រុមប្រឹក្សាភិបាលបំពេញបេសកកម្មនេះគឺការិយាល័យសាលាឆាធ័រ (CSO) ដែលជួយក្រុមគ្រួសារក្នុងការសម្រេចចិត្តដែលមានការយល់ដឹងអំពីជម្រើសរបស់ពួកគាត់សម្រាប់ការចូលរៀននៅសាលាឆាធ័រ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា និងធ្វើឱ្យសាលាឆាធ័រទទួលខុសត្រូវចំពោះគោលដៅដ៏មហិច្ឆតា។ ការិយាល័យសាលាឆាធ័រលើកកម្ពស់ស្តង់ដារខ្ពស់ និងផ្តល់ការគាំទ្រដែលសំខាន់ ខណៈពេលដែលរក្សាសេរីភាពនៃសាលាឆាធ័រ និងការពារសិទ្ធិរបស់សិស្ស និងក្រុមគ្រួសារ ផងដែរ។ ការិយាល័យសាលាឆាធ័រដឹកនាំដោយលោក Peng Chao ប្រធានស្តីទីនៃការិយាល័យសាលាឆាធ័រ និងរួមមានបុគ្គលិកប្រហែល ១៦ នាក់ ទៀត។

លោក Chao មានស្រសាសន៍ថា «ក្រុមការងារ ការិយាល័យសាលាឆាធ័រ បានប្តេជ្ញាចិត្តក្នុងការគាំទ្រសិស្សានុសិស្ស និងក្រុមគ្រួសារ នៅពេលពួកគេរុករកតំបន់ឆាធ័រនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា និងធ្វើឱ្យប្រាកដថាសិស្សទាំងអស់អាចចូលទៅកាន់សាលាដែលជំរុញពួកគេក្នុងការសិក្សា គាំទ្រសុខុមាលភាពរបស់ពួកគេ និងត្រៀមពួកគេឱ្យទទួលជោគជ័យ»។

ក្នុងនាមក្រុមប្រឹក្សាភិបាល ការិយាល័យសាលាឆាធ័រ ធ្វើការត្រួតពិនិត្យសាលាឆាធ័រនីមួយៗយ៉ាងពេញលេញប្រចាំឆ្នាំ ហើយនៅពេលដែលសាលាឆាធ័រសុំបន្តទៀត ត្រូវបង្ហាញការវាយតម្លៃដ៏ទូលំទូលាយ និងរបាយការណ៍សុំបន្តទៀតទៅឱ្យក្រុមប្រឹក្សាភិបាល។ ការពិនិត្យឡើងវិញនេះ និងរបាយការណ៍វាយតម្លៃសុំបន្តរបស់ ការិយាល័យសាលាឆាធ័រ ផ្អែកលើគម្រោងលទ្ធផលរបស់សាលាឆាធ័រ ដែលវាយតម្លៃបីផ្នែក ឬក្នុងវិស័យបី។ ទាំងនោះគឺ៖

- ជោគជ័យក្នុងការសិក្សា
- ការអនុលោមតាមគោលការណ៍របស់ក្រសួង និងការសម្រេចបាន
- ការចាត់ចែងហិរញ្ញវត្ថុ និងការអាចទ្រទ្រង់បាន។

ច្បាប់សាលាឆាធ័រអនុញ្ញាតជាចម្បងសម្រាប់ការបន្តឆាធ័រសម្រាប់រយៈពេលប្រាំឆ្នាំ។ ក្នុងកាលៈទេសៈមានកំណត់ សាលាឆាធ័រក្នុងទីក្រុងហ្វីឡាដែលហ្វ្យា អាចត្រូវបានបន្តសម្រាប់រយៈពេលមួយឆ្នាំ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃព័ត៌មានអំពីលទ្ធផលនៃការសិក្សាបន្ថែម។

ការិយាល័យសាលាឆាធ័រ ប្រើក្របខ័ណ្ឌនៃការបន្តឆាធ័រដូចគ្នា ក្នុងការត្រួតពិនិត្យ វាយតម្លៃ និងប៉ាន់ប្រមាណ ដែលកំពុងមានជាបន្ត។ អគារសាលាឆាធ័រនីមួយៗដែលគ្មាននៅក្នុងក្រុមបន្តទទួលការវាយតម្លៃប្រចាំឆ្នាំនៃលទ្ធផលរបស់ខ្លួនដែលធ្វើបាន ក្នុងទម្រង់នៃរបាយការណ៍វាយតម្លៃឆាធ័រប្រចាំឆ្នាំ (ACE)។

បច្ចុប្បន្ននេះមានអគារសាលាឆាធ័រចំនួន ៨៣ នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលបង្រៀនសិស្សប្រមាណ 65,000 នាក់។ ខណៈពេលដែលក្រសួងអប់រំមានសាលាចំនួន ២១៧ ដែលចុះឈ្មោះសិស្សប្រហែល 115,000 នាក់។ សិស្សបន្ថែមត្រូវបានចុះឈ្មោះនៅសាលាតាមជម្រើសផ្សេងៗ និងសាលាឆាធ័រ ផ្សេងទៀត/រៀនតាមអ៊ិនធ័រណិត។ ការចុះឈ្មោះចូលរៀនសរុបសម្រាប់ក្រសួងអប់រំគឺសិស្សចំនួន 198,645 នាក់។

ច្បាប់សាលាឆាធ័រក្នុងរដ្ឋផិនស៊ីលវេនញ៉ា ត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៧ ដើម្បីអនុញ្ញាតឱ្យក្រុមប្រឹក្សាសាលាក្នុងតំបន់បង្កើតសាលាឆាធ័រថ្មី។ ហើយនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា សាលាឆាធ័រទីមួយបានបើកនៅឆ្នាំ ២០០២។ ភាគច្រើន សាលាឆាធ័រប្រហាក់ប្រហែលនឹងសាលារបស់ក្រសួងអប់រំ រួមមាន៖

- ជាសាលាសាធារណៈ គ្មានថ្លៃសាលា។
- ជាសាលាដែលផ្តល់ការបង្ហាត់បង្រៀនក្នុងមុខវិជ្ជាសំខាន់ៗទាំងអស់ ស្របតាមតម្រូវការរបស់រដ្ឋ។
- ជាសាលាដែលត្រូវតែចុះឈ្មោះសិស្ស និងគាំទ្រសិស្សទាំងអស់ រួមទាំងសិស្សដែលមានតម្រូវការពិសេស និងមិនសូវចេះភាសាអង់គ្លេស។

ម៉្យាងវិញទៀត សាលាឆាធ័រមិនចាំបាច់ធ្វើតាមគោលការណ៍របស់ក្រសួងអប់រំមួយចំនួននោះទេ ដូចជា៖

- ការរៀបចំកម្មវិធីសិក្សារបស់ពួកគេ
- រយៈពេលនៃ ថ្ងៃសិក្សា និងឆ្នាំសិក្សា (តែពួកគេត្រូវតែបំពេញតាមតម្រូវការរបស់រដ្ឋ)
- ការជ្រើសរើសសៀវភៅសិក្សា កម្មវិធីសិក្សា និងសម្ភារៈសិក្សាផ្សេងៗទៀត
- ការជួលគ្រូ និងបុគ្គលិក
- ការរំពឹងទុកខាងការដាក់វិន័យសិស្ស និង
- កម្មវិធីក្រៅកម្មវិធីសិក្សា។

គោលការណ៍ លេខ 400 របស់ក្រុមប្រឹក្សាភិបាល ផ្តល់អំណាចឱ្យក្រុមប្រឹក្សាភិបាលលើការអនុញ្ញាតសាលាឆាធ័រ ព្រមទាំងការបង្កើត និងរក្សារបៀបត្រួតពិនិត្យដែលមានសមត្ថភាព និងមានប្រសិទ្ធភាព។ លើសពីនេះ គោលការណ៍ លេខ 401 របស់ក្រុមប្រឹក្សាភិបាល ធ្វើឱ្យប្រាកដថាស្តង់ដារអនុញ្ញាតសាលា

ឆាផ់រទាំងអស់មានតម្លាភាព ផ្អែកលើគុណសម្បត្តិ ទូលំទូលាយ មានសមភាព និងពិចារណាពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ក្នុងការបែងចែកធនធានដែលមានកម្រិតដល់សាលារដ្ឋទាំងអស់នៅក្នុងទីក្រុងហ្វីឡាដែលហ្យ៉ា។ ដើម្បីស្វែងយល់បន្ថែមអំពីការិយាល័យសាលាឆាផ់រ សូមចូលទៅកាន់គេហទំព័ររបស់ការិយាល័យសាលាឆាផ់រ [webpage]() ។

## ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរីកចម្រើននៃការសម្រេចតាម គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails)

នៅក្នុងកិច្ចប្រជុំដើម្បីស្វែងយល់បន្ថែមកាលពីថ្ងៃទី ២៦ ខែ មករា ក្រុមប្រឹក្សាអប់រំបានផ្តល់ព័ត៌មានថ្មីៗសម្រាប់ពេលជាច់ឆ្នាំ លើវគ្គត្រួតពិនិត្យការរីកចម្រើននៃ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails) ដែលបានធ្វើក្នុងឆ្នាំ ២០២២។ កាលពីឆ្នាំមុន ក្រុមប្រឹក្សាភិបាលបានត្រួតពិនិត្យការរីកចម្រើនសម្រាប់ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ (Goals) ទាំងប្រាំ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Guardrails) ទាំងបួន។ ជាការរំលឹក Goals & Guardrails គឺជាផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល ក្នុងការបង្កើនជោគជ័យរបស់សិស្ស។ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ (Goals) ទាំងប្រាំ ផ្តោតលើ ការអាន គណិតវិទ្យា និងការត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ និងអាជីព។ ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Guardrails) កំណត់ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការសិក្សា។ តម្រូវឱ្យមានអ្វីៗទាំងអស់នេះ៖

- សាលាដែលមានការស្វាគមន៍ និងមានការគាំទ្រ
- សាលាដែលមានបទពិសោធន៍ច្រើន និងមានការអភិវឌ្ឍន៍
- ភាពជាដៃគូជាមួយ ឪពុកម្តាយ/សមាជិកគ្រួសារ និង
- ដោះស្រាយការប្រកាន់ពូជសាសន៍។

ក្នុងខែធ្នូ ក្រុមប្រឹក្សាភិបាលបានតាមដានការរីចម្រើនទៅកាន់ការសម្រេចបាន ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យទី ៣ (Guardrail 3)៖ មាតាបិតា និងអាណាព្យាបាលគ្រប់រូបនឹងត្រូវបានស្វាគមន៍ និងសុំឱ្យក្លាយជាដៃគូនៅក្នុងសហគមន៍របស់កូនគាត់។ ក្រុមប្រឹក្សាភិបាលបានពិនិត្យមើលការបង្ហាញលទ្ធផលដែលធ្វើបានចំនួនពីរ សម្រាប់ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យនេះ។

ការចង្អុលបង្ហាញទី ១ ដែលជាភាគរយនៃសាលារៀនដែលមាន «ពិន្ទុទំនាក់ទំនង (Relationship Score)» ខ្ពស់ លើការស្ទង់មតិទូទាំងក្រសួងគឺមិនបានតាមការចង់បានទេ។ ការរីកចម្រើនលើ ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ ត្រូវបានរារាំងដោយអត្រាការចូលរួមការស្ទង់មតិទាបនៅតាមសាលា។ លើសពីនេះ សាលាចំនួន ៧៥ នៅខ្វះតែមួយពិន្ទុអាចត្រូវតាមពិន្ទុទំនាក់ទំនងខ្ពស់។

ទាក់ទងនឹងការចង្អុលបង្ហាញលទ្ធផលដែលធ្វើបានទីពីរ ដែលជាភាគរយនៃសាលារៀនដែលមានក្រុមប្រឹក្សាសាលា (SAC) ដែលជួបជុំគ្នាបួនដង ឬច្រើនជាងនេះ ក្នុងមួយឆ្នាំ ក្រសួងអប់រំនឹងអាចធ្វើបានតាមការចង់បាន ១០០% នៅឆ្នាំសិក្សា ២០២៥-២០២៦។

លោកអ្នកអាចអានរបាយការណ៍តាមដានពីការរីកចម្រើននៃ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals & Guardrails) ប្រចាំខែរបស់យើងទាំងអស់ នៅទីនេះ.។

## កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនាពេលខាងមុខ

ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ - កិច្ចប្រជុំដើម្បីស្វែងយល់បន្ថែម
ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០២៣ - កិច្ចប្រជុំដើម្បីស្វែងយល់បន្ថែម និងការអនុម័តនៃការបង់ថ្លៃសរុប
ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០២៣ - សវនាការអំពីថវិកា
ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២៣ - កិច្ចប្រជុំដើម្បីស្វែងយល់បន្ថែម

## អំពីក្រុមប្រឹក្សាអប់រំ

ក្រុមប្រឹក្សាភិបាលអប់រំគឺជាស្ថាប័នគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគោលការណ៍ និងការសម្រេចចិត្តលើថវិកាទាំងអស់ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ លើសពីនេះ ក្រុមប្រឹក្សាភិបាលអប់រំមានតួនាទីជាអ្នកផ្តល់សិទ្ធិសម្រាប់សាលាឆាធ័រទាំងអស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា។ ក្រុមប្រឹក្សាភិបាលមានសមាជិកប្រាំបួននាក់ ដែលត្រូវបានតែងតាំងដោយចៅហ្វាយក្រុង និងបញ្ជាក់ដោយក្រុមប្រឹក្សាក្រុង។ សមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្នគឺ៖ Reginald L. Streater, ប្រធាន; Mallory Fix-Lopez, អនុប្រធាន; Sarah-Ashley Andrews; Julia Danzy; Leticia Egea-Hinton; Chau Wing Lam; Lisa Salley; Cecelia Thompson និង Joyce S. Wilkerson។

**សូមអរគុណចំពោះការអានព្រឹត្តិបត្ររបស់យើង!**

សូមអរគុណចំពោះការចំណាយពេលអានព័ត៌មានរបស់យើង និងតភ្ជាប់ទំនាក់ទំនងជាមួយក្រុមប្រឹក្សាអប់រំ។ ប្រសិនបើលោកអ្នកមានមតិយោបល់ ឬសំណួរអ្វី សូមផ្ញើអ៊ីមែលមកយើងតាមរយៈ schoolboard@philasd.org ។